# របាយការណ៍នៃវគ្គបណ្តុះបណ្តាល
# ស្តីអំពី
# កម្មវិធីកុំព្យូទ័រភាសាខ្មែរ

## I) *ព័ត៌មានសង្ខេបនៃវគ្គបណ្តុះបណ្តាល៖*

- កាលបរិច្ឆេទ៖ ថ្ងៃទី១៧ ដល់ ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០០៧
- ម៉ោងសិក្សា៖ ម៉ោង ៨.០០ ដល់ ១២.០០ ថ្ងៃត្រង់
- រយៈពេលសិក្សា៖ ២០ ម៉ោង
- ស្ថាប័នរៀបចំវគ្គបណ្តុះបណ្តាល៖ អង្គការវិទ្យាស្ថានបើកទូលាយ
- ទីកន្លែងបណ្តុះបណ្តាល៖ អង្គការវិទ្យាស្ថានបើកទូលាយ
- ស្ថាប័នរបស់អ្នកសិក្សា៖ ក្រសួងមហាផ្ទៃ
- ចំនួនសិក្ខាកាម៖ ១៥ រូប (ស្ត្រី២ រូប)

## II) *សេចក្តីផ្តើម៖*

ក្នុងការចូលរួមកសាងសមត្ថភាព ផ្នែកបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា ដល់មន្ត្រីរដ្ឋាភិបាល និងបុគ្គលិកអង្គការ ស្ថាប័ននានា គម្រោងកម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ បានបើកវគ្គបណ្តុះបណ្តាលមួយ ស្តីអំពី ការប្រើប្រាស់កុំព្យូទ័រជាភាសាខ្មែរ ជូនដល់មន្ត្រី នៃទីស្តីការក្រសួងមហាផ្ទៃ ចំនួន១២រូប ដែលក្នុងនោះមាន ១រូប ជាស្ត្រី។

## III) *គោលបំណងនៃវគ្គបណ្តុះបណ្តាល*៖

គោលបំណង នៃវគ្គបណ្តុះបណ្តាលនេះគឺ ៖

- កសាងសមត្ថភាពដល់បុរសនិងស្ត្រីទៅលើផ្នែកបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បង្កើន ជំនាញក្នុងការប្រើប្រាស់ និងដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ

## IV) *កម្មវិធីសិក្សាដែលបានសិក្សា៖*

ក្នុងរយៈពេល ៥ថ្ងៃ នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំងអស់ បានសិក្សាស្វែងយល់បន្ថែម អំពី៖

- ការណែនាំអំពីកម្មវិធីកុំព្យូទ័រភាសាខ្មែរ

- របៀបវាយអក្សរខ្មែរតាមក្បួនយូនីកូដខ្មែរ
- ការប្រើប្រាស់កម្មវិធីការិយាល័យខ្មែរ៖
  - ➢ ស្លឹករឹត (OpenOffice.org Writer)
  - ➢ នព្វន្ត (OpenOffice.org Calc)
  - ➢ ពិព័រណ៌ (OpenOffice.org Impress)
- ការណែនាំអំពីការប្រើប្រាស់កម្មវិធីរុករកបណ្ដាញអ៊ីនធឺណិត (មេខលា) និង អ៊ីមែល (មយូរា) ភាសាខ្មែរ
- សិក្សារបៀបដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ

### *V) ការវាយតម្លៃវគ្គបណ្ដុះបណ្ដាល៖*

#### ការវាយតម្លៃរបស់លោកគ្រូបណ្ដុះបណ្ដាល៖

យោងតាមលទ្ធផលនៃការប្រលងបញ្ចប់វគ្គ សិក្ខាកាមទាំងអស់បានប្រលងជាប់ជាស្ពាពរ។ សិក្ខាកាមមួយភាគធំ អាចវាយអក្សរខ្មែរតាមក្បួនយូនីកូដខ្មែរ និងប្រើប្រាស់កម្មវិធីស្លឹករឹតបានល្អ និងកម្មវិធីនព្វន្ត ពិព័រណ៌ បានជាមធ្យម ព្រមទាំងសិក្សាបន្ថែមពីរបៀបដំឡើងកម្មវិធីកុំព្យូទ័រជាភាសាខ្មែរផងដែរ។ ព្រមជាមួយគ្នានេះផងដែរ លោកគ្រូបណ្ដុះបណ្ដាល បានកត់សំគាល់ឃើញថា សិក្ខាកាមទាំងអស់បានខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់ចំពោះវគ្គបណ្ដុះបណ្ដាលជាខ្លាំង។

#### ការវាយតម្លៃរបស់សិក្ខាកាម៖

សិក្ខាកាមទាំងអស់បានវាយតម្លៃខ្ពស់ចំពោះវគ្គបណ្ដុះបណ្ដាលនេះ ដោយពួកគាត់បានមានប្រសាសន៍ថា ពួកគាត់ទទួលបាននូវជំនាញ និងចំណេះដឹងបន្ថែមទៅលើការប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ហើយអ្វីដែលពិសេសនោះ កម្មវិធីសិក្សាទាំងអស់នេះសុទ្ធតែជាភាសាខ្មែរ ។

ទន្ទឹមនឹងនោះ ពួកគាត់ក៏បានចូលរួមផ្ដល់ជាមតិយោបល់ ដើម្បីកែលម្អវគ្គបណ្ដុះបណ្ដាល ដោយស្នើសុំឲ្យមានវគ្គបណ្ដុះបណ្ដាលនេះមានរយៈពេលវែងជាងនេះ ដើម្បីឲ្យពួកគាត់ទាំងអស់មានពេលគ្រប់គ្រាន់ដើម្បីអនុវត្ត។

### *VI) សេចក្ដីបញ្ចប់៖*

វគ្គបណ្ដុះបណ្ដាលនេះ បានបញ្ចប់ដោយជោគជ័យ និងគួរជាទីមោទនៈ។ ក្រុមការងារស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ បានសំដែងនូវសេចក្ដីថ្លែងអំណរគុណ ចំពោះការចូលរួមយ៉ាងសកម្មរបស់សិក្ខាកាមព្រមទាំងទទួលបាននូវលទ្ធផលល្អក្នុងការប្រលងបញ្ចប់វគ្គ ក្នុងវគ្គបណ្ដុះបណ្ដាលកម្មវិធីការិយាល័យជាភាសាខ្មែរ និងការប្រើប្រាស់ កម្មវិធីរុករកបណ្ដាញអ៊ីនធឺណិត

(មេខលា) និងអ៊ីមែល (មយូរា) ជាភាសាខ្មែរ ។ អង្គការវិទ្យាស្ថានបើកទូលាយសង្ឃឹមថា សិក្ខាកាម ទាំងអស់នឹងយកចំណេះដឹងទាំងនេះទៅប្រើប្រាស់ដើម្បីបង្កើនគុណភាពការងាររបស់ពួកគេ។

អ្នកធ្វើរបាយការណ៍៖
កញ្ញា ប្រាក់ សុខាយុ អ្នកសម្របសម្រួលកម្មវិធីស្ត្រី

ពិនិត្យនិងកែសម្រួលដោយ៖

លោកស្រី ជឹម ម៉ាណាវី នាយិកាប្រតិបត្តិ

VII) ***តារាងឈ្មោះអ្នកសិក្ខាកាម***

| ល.រ | ឈ្មោះជាភាសាខ្មែរ | ភេទ | មកពីស្ថាប័ន | មុខងារ |
|---|---|---|---|---|
| ១ | ទូន សំណាង | ប្រុស | ការិយាល័យកិច្ចការនយោបាយ និងសិទ្ធមនុស្ស នៃនាយកកិច្ចការនយោបាយ | អនុប្រធានការិយាល័យ |
| ២ | មុំ ប៉ុណ្ណកា | ប្រុស | ការិយាល័យតម្កល់ឯកសារ នៃអគ្គលេខាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល | នាយរងការិយាល័យ |
| ៣ | កាន់ សុវណ្ណី | ស្រី | ការិយាល័យរដ្ឋបាល និងសរុប នៃនាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធានការិយាល័យ |
| ៤ | ឡេង វ៉ាវង្ស | ប្រុស | ការិយាល័យរដ្ឋបាល នៃន.រដ្ឋបាលមូលដ្ឋាន | មន្ត្រី |
| ៥ | លី ស៊ីនហាវ | ប្រុស | នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន | មន្ត្រី |
| ៦ | សំរឿន សំរស់មករា | ប្រុស | អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ នាយកដ្ឋានមធ្យោបាយ នៃអ.គ.នពន្ធនាគារ | មន្ត្រី |
| ៧ | ជា វិចិត្រតនះ | ប្រុស | នាយកដ្ឋានហិរញ្ញវត្ថុ នៃអ.គ.នភស្តុភារ និងហិរញ្ញវត្ថុ | មន្ត្រី |
| ៨ | ភឿង ច័ន្ទា | ប្រុស | នាយកដ្ឋានហិរញ្ញវត្ថុ នៃអ.គ.នភស្តុភារ និងហិរញ្ញវត្ថុ | មន្ត្រី |
| ៩ | ឡុង សុជាតិ | ប្រុស | លេខាធិការដ្ឋាន នៃអ.គ.នពន្ធនាគារ | អនុប្រធានការិយាល័យ |
| ១០ | គី វិសិទ្ធ | ប្រុស | សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | នាយផ្នែក |
| ១១ | ស៊ុយ សាឡាត់ | ប្រុស | សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | នាយផ្នែក |
| ១២ | សែម ជា | ប្រុស | សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | នាយផ្នែក |

សិក្ខាកាមទាំងអស់បានប្រលងបញ្ចប់វគ្គជាប់ជាស្ថាពរ និងបានទទួលនូវវិញ្ញាបនបត្របញ្ជាក់ការសិក្សាគ្រប់គ្រប់គ្នា។